## ខ្លឹមសារសង្ខេបអត្ថបទ
## សិទ្ធិទទួលបានតំណាងផ្លូវច្បាប់ (មេធាវី)

Johann Bair, The International Covenant on Civil and Political Rights and Its (First) Optional Protocol, A Short Commentary Based on Views, General Comments and Concluding Observations by the Human Rights Committee, pp. 63-64, 2005

**បទប្បញ្ញត្តិ៖** មាត្រា១៤ (៣.ខ) នៃកតិកាសញ្ញា៖ ៣.*ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើ ភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖ ...(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។...*

**១.** កថាខ័ណ្ឌទី៣ (ខ) នៃមាត្រា១៤ ធានាសិទ្ធិមានតំណាងផ្លូវច្បាប់។ ជនជាប់ចោទ មានសិទ្ធិមានជំនួយផ្លូវច្បាប់ តាមជម្រើស និងលទ្ធភាពដែលមាន។ ទោះបីជាយ៉ាងណាក្តី ក្នុងករណីមិនមានមធ្យោបាយ (ក្រីក្រ) ចៅក្រម ត្រូវតែងតាំងជំនួយផ្លូវច្បាប់ (មេធាវី) ដោយមិនយកម្រៃ ក្នុងករណី ផលប្រយោជន៍នៃយុត្តិធម៌តម្រូវ ជាពិសេស ករណីសម្រាប់បទឧក្រិដ្ឋ។ ក្នុងករណីមានការផ្តន្ទាទោសប្រហារជីវិត ត្រូវតែមានមេធាវីជួយក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី និងធានាឱ្យមានវត្តមានរបស់មេធាវីក្នុងសំណុំរឿងប្រហារជីវិតនេះ។ ចៅក្រម ត្រូវធានាថា មេធាវីតែងតាំងដោយខ្លួនប្រព្រឹត្តស្របនឹងផលប្រយោជន៍នៃយុត្តិធម៌។ ក្នុងករណីមេធាវីតែងតាំង មិនបានប្រព្រឹត្តត្រឹមត្រូវ ជនជាប់ចោទ អាចទទួលបានមេធាវីផ្សេងទៀតបាន។

**២.** តំណាងត្រូវតែមានប្រសិទ្ធភាព (effective representation) និងគ្រប់គ្រាន់ ក្នុងន័យថា មេធាវីអាចផ្តល់ព័ត៌មាន និងផ្តល់ប្រឹក្សាដល់កូនក្តី។ តុលាការ ត្រូវជូនដំណឹងដល់មេធាវី ដូចជា ថ្ងៃសវនាការ។ ក្នុងករណីមិនអាចចូលរួម មេធាវីអាចស្នើសុំពន្យាពេលសវនាការ។

**៣.** ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ត្រូវធានាថាមេធាវីបានប្រឹក្សាយោបល់ជាមួយនឹងកូនក្តី។

**ខ្លឹមសារដកស្រង់៖** ១. *តុលាការត្រូវធានាថាទង្វើនៃសវនាការ ដោយមេធាវី ស្របនឹងផលប្រយោជន៍នៃយុត្តិធម៌។* ២. *ជាទូទៅ រដ្ឋភាគីមិនទទួលខុសត្រូវចំពោះកំហុសរបស់មេធាវី....។ វាមិនមែនជាករណីកិច្ចរបស់រដ្ឋភាគី ក្នុងការស៊ើបអង្កេតលើសេចក្តីសម្រេចបែបវិជ្ជាជីវៈរបស់មេធាវីទេ។*

**ពាក្យគន្លឹះ៖** ការការពារប្រកបដោយប្រសិទ្ធភាព, ទោសប្រហារជីវិត, តំណាងតាមផ្លូវច្បាប់។